ការរ៉ាប់រងលើការថែទាំរយៈពេលវែងក្នុងតម្លៃសមរម្យសម្រាប់អ្នកធ្វើការក្នុងរដ្ឋវ៉ាស៊ីនតោន

WA CARES FUND

មូលនិធិថែទាំនៃរដ្ឋវ៉ាស៊ីនតោន (WA Cares Fund) គឺជាអត្ថប្រយោជន៍ត្រូវទទួលបាន ដែលបង្កើតឡើងដើម្បីជួយអ្នកឱ្យចម្រើនវ័យចាស់ដោយឯករាជ្យក្នុង ផ្ទះរបស់អ្នកផ្ទាល់។ ពួកយើងភាគច្រើននឹងត្រូវការការថែទាំរយៈពេលវែង ដើម្បីជួយដល់សកម្មភាពប្រចាំថ្ងៃដូចជា ងូតទឹក ទទួលទាន ធ្វើដំណើរ និងគ្រប់គ្រងការប្រើឱសថ (ថ្នាំពេទ្យ) ប៉ុន្តែនឹងមិនចាំបាច់ចំណាយប្រាក់ឡើយ។

Medicare និងធានារ៉ាប់រងសុខភាពមិនរ៉ាប់រងលើ ការថែទាំរយៈពេលវែងទេ ហើយជាធម្មតា Medicaid តម្រូវឱ្យ អ្នកចំណាយប្រាក់សន្សំរហូតដល់ ២,០០០ ដុល្លារ ដើម្បីមានសិទ្ធិទទួលបាន។ WA Cares ផ្តល់ធនធានដ៏សំខាន់ដើម្បី ផ្តល់ជម្រើសបន្ថែមដល់អ្នកអំឡុងដំណាក់កាលមួយក្នុងចំណោមដំណាក់កាលទន់ខ្សោយបំផុតក្នុងជីវិត។

របៀបដែលវាដំណើរការ

ចូលរួមវិភាគទានដោយស្ម័យប្រវត្តិ



ចូលរួមវិភាគទាន ០.៥៨% នៃ ប្រាក់ខែរបស់អ្នកអំឡុង ឆ្នាំធ្វើការរបស់អ្នក។

មានសិទ្ធិទទួលបានអត្ថប្រយោជន៍



ដាក់ពាក្យស្នើសុំអត្ថប្រយោជន៍ ប្រសិនបើអ្នកមានគ្រប់លក្ខខណ្ឌចូលរួមវិភាគទាន និងតម្រូវការថែទាំ។

ប្រើអត្ថប្រយោជន៍របស់អ្នក



ជ្រើសរើសថាត្រូវប្រើអត្ថប្រយោជន៍ ពេញមួយជីវិតចំនួន ៣៦,៥០០ ដុល្លារ របស់អ្នកបែបណា(កើនឡើងដោយមានអតិផរណា)។

ការមានសិទ្ធិទទួលបានអត្ថប្រយោជន៍

អ្នកត្រូវតែបំពេញតាមលក្ខខណ្ឌពីរ ដើម្បីទទួលបាន អត្ថប្រយោជន៍។

១. លក្ខខណ្ឌចូលរួមវិភាគទាន (ដាក់តាមតម្រូវការ)

អ្នកអាចបំពេញតាមលក្ខខណ្ឌចូលរួមវិភាគទាន តាមរយៈវិធីមួយក្នុងចំណោមបី។

- **វិធីអចិន្ត្រៃយ៍៖** ទទួលបានចំនួនទឹកប្រាក់ពេញនៃអត្ថប្រយោជន៍ ដោយចូលរួមវិភាគទានយ៉ាងតិច ១០ ឆ្នាំ។*
- **វិធីបណ្តោះអាសន្ន៖** ទទួលបានចំនួនទឹកប្រាក់ពេញនៃអត្ថប្រយោជន៍ ប្រសិនបើអ្នកបានចូលរួមវិភាគទានយ៉ាងតិច ប៊ី ក្នុងចំណោមប្រាំមួយឆ្នាំចុងក្រោយ* នៅពេលដែលអ្នកដាក់ពាក្យស្នើសុំអត្ថប្រយោជន៍។
- **វិធីបណ្តាក់៖** ប្រសិនបើអ្នកបានកើតមុន ឆ្នាំ ១៩៦៨ នោះទទួលបានពេញមួយជីវិតនូវ ១០% នៃចំនួនទឹកប្រាក់ពេញនៃអត្ថប្រយោជន៍ សម្រាប់ឆ្នាំនីមួយៗ*ដែលអ្នកចូលរួមវិភាគទាន។

*យើងនឹងរាប់ឆ្នាំប្រតិទិននីមួយៗដែលអ្នកធ្វើការ យ៉ាងតិច ៥០០ ម៉ោង។

អ្នកអាចចាកចេញពីរដ្ឋបានហើយអ្នកនិងអាចបន្តទទួលបានអត្ថប្រយោជន៍នៅពេលដែលអ្នកត្រូវការការថែទាំ។

២. លក្ខខណ្ឌនៃតម្រូវការថែទាំ

យើងត្រូវតែកំណត់ថា អ្នកត្រូវការជំនួយសម្រាប់សកម្មភាពរស់នៅប្រចាំថ្ងៃចាប់ពីបីឡើងទៅ ហើយនឹងបន្តត្រូវការជំនួយយ៉ាងតិច ៩០ថ្ងៃ។ សកម្មភាពដែលយើងវាយតម្លៃគឺ៖

- ងូតទឹក
- បម្លាស់ទីលើគ្រែ
- ផ្ទេរទីតាំង (ផ្លាស់ទីចូល ឬ ចេញពីកៅអី)
- ប្រើបន្ទប់ទឹក
- បម្លាស់ទី (ដើរ ឬ ទៅណាមកណា)
- ទទួលទាន
- គ្រប់គ្រង ការប្រើឱសថ (ថ្នាំពេទ្យ)

យើងនឹងរាប់សកម្មភាពដែលអ្នកត្រូវការ ការមើលការខុសត្រូវ (ដូចជាឃ្លាំមើល ផ្តល់តម្រុយ ឬជំនួយ ក្នុងការដំឡើង) ដើម្បីធ្វើសកម្មភាពនោះបាន។

ការដាក់ពាក្យស្នើសុំអត្ថប្រយោជន៍

ដើម្បីចាប់ផ្តើមដំណើរការនេះ អ្នក (ឬនរណាម្នាក់ដែលជួយអ្នក) អាចបង្កើតគណនីអត្ថប្រយោជន៍ WA Cares ដោយចូលទៅកាន់ wacaresfund.wa.gov/apply។

នៅពេលយើងបញ្ជាក់ថា អ្នកបានបំពេញតាមលក្ខខណ្ឌចូលរួមវិភាគទានហើយ អ្នកនឹងត្រូវកំណត់ពេលវេលាដើម្បីជួបផ្ទាល់ ដើម្បីពិភាក្សាអំពីតម្រូវការថែទាំរបស់អ្នក។ បន្ទាប់មក យើងនឹងជម្រាបអ្នកថាតើអ្នកត្រូវបានយល់ព្រមឱ្យប្រើអត្ថប្រយោជន៍ឬអត់។

ចូលទៅកាន់ wacaresfund.wa.gov/benefits ដើម្បីស្វែងយល់បន្ថែម។

ការប្រើអត្ថប្រយោជន៍របស់អ្នក

អ្នកអាចប្រើអត្ថប្រយោជន៍របស់អ្នក ដើម្បីទទួលបានសេវាកម្មដែលត្រូវបានរ៉ាប់រង និងជំនួយពីអ្នកផ្តល់សេវា WA Cares។

ដើម្បីជួយអ្នកក្នុងការស្នាក់នៅផ្ទះ

- ការថែទាំនៅផ្ទះដោយអ្នកផ្តល់សេវាលក្ខណៈបុគ្គល ឬទីភ្នាក់ងារថែទាំនៅផ្ទះ
- ការវាយតម្លៃសុវត្ថិភាពនៅផ្ទះ
- ការកែសម្រួលផ្ទះ
- អាហារដឹកជញ្ជូនដល់ផ្ទះ
- ការដឹកជញ្ជូន
- ឧបករណ៍ និងបច្ចេកវិទ្យាដែលមានភាពបត់បែន
- ប្រព័ន្ធសង្គ្រោះបន្ទាន់ផ្ទាល់ខ្លួន
- កិច្ចការផ្ទះ និងកិច្ចការទីធ្លាសួនច្បារ

ដើម្បីជួយដល់អ្នកថែទាំក្នុងគ្រួសាររបស់អ្នក

- ការថែទាំដោយគិតថ្លៃពីមនុស្សជាទីស្រឡាញ់ រួមទាំង ប្តីឬប្រពន្ធរបស់អ្នក
- ការថែទាំជំនួសបណ្តោះអាសន្នក្នុងផ្ទះរបស់អ្នក ឬមណ្ឌល
- ការអប់រំ និងការប្រឹក្សាដើម្បីជួយ គ្រប់គ្រងការថែទាំរបស់អ្នក
- ជំនួយគ្រប់គ្រងឥរិយាបថ និងការភ្លេចភ្លាំងច្រើន
- ការសម្របសម្រួលដល់ការផ្ទេរការថែទាំ ដើម្បីជួយអ្នក នៅពេលអ្នកចាកចេញពីមណ្ឌល ឬមន្ទីរពេទ្យ

ក្នុងសហគមន៍របស់អ្នក

- ផ្ទះគ្រួសារមនុស្សពេញវ័យ
- សេវាកម្មពេលថ្ងៃសម្រាប់មនុស្សពេញវ័យ

នៅក្នុងមណ្ឌល

- សេវាកម្មរស់នៅដោយមានជំនួយ រួមទាំង សេវាកម្មថែទាំការចងចាំ
- មណ្ឌលចាស់ជរា

សេវាកម្មមួយចំនួនប្រហែលមិនមានទូទាំងរដ្ឋទេ។

រកជំនួយ

អ្នកអាចទាក់ទងមកយើងពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពីម៉ោង ៨:៣០ ព្រឹកដល់ ៤:៣០ រសៀល (បិទនៅថ្ងៃបុណ្យរដ្ឋ)។ សម្រាប់ព័ត៌មានថ្មីៗ សូមចូលមើល wacaresfund.wa.gov។



លេខទូរសព្ទ
៨៤៤-CARE៤WA (៨៤៤-២២៧-៣៤៩២)



ផ្ញើអ៊ីមែល ឬសារជជែក
ចូលទៅកាន់ wacaresfund.wa.gov/contact

សម្រាប់ TTY/ TDD ឬសេវាកម្មបញ្ជូនបន្តនៃរដ្ឋវ៉ាស៊ីនតោន សូមទូរសព្ទទៅលេខ ៧១១។ ជំនួយផ្នែកភាសាមានផ្តល់ជូនតាមទូរសព្ទ ឬអ៊ីមែល។